# សុន្ទរកថា

## ឯកឧត្តម ស ខេង

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ក្នុងពិធីបើកសន្និបាតបូកសរុបការងារឆ្នាំ ២០០៩

## និងលើកទិសដៅការងារឆ្នាំ ២០១០ របស់ក្រសួងមហាផ្ទៃ

( ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០១០ )

**៚គណៈអធិបតី ឯកឧត្តម លោកជំទាវ លោកឧត្តមសេនីយ៍ អស់លោក លោកស្រី សមាជិក សមាជិកា អង្គសន្និបាតទាំងមូល ជាទីមេត្រី !**

ថ្ងៃនេះ យើងជួបជុំគ្នាដើម្បីប្រារព្ធពិធីបើកសន្និបាតបូកសរុបការងារប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ ដើម្បីរួមគ្នាធ្វើការវាយតម្លៃអំពីសមិទ្ធផល បញ្ហាប្រឈមក្នុងការអនុវត្តការងារក្នុងឆ្នាំ២០០៩កន្លងមក និងផ្តួចផ្តើមរួមគ្នាលើកឡើងអំពីទិសដៅការងារក្នុងឆ្នាំ២០១០ រួមទាំងការផ្តួចផ្តើមអំពីវិធានការនានា ក្នុងការដោះស្រាយបញ្ហាប្រឈមដែលសេសសល់ពីឆ្នាំ២០០៩ សំរាប់លើកកំពស់ការអនុវត្តការងារក្នុងឆ្នាំ២០១០នេះ ឱ្យកាន់តែសំរេចបានសមិទ្ធផលល្អប្រសើរថែមទៀត ។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមស្វាគមន៍ចំពោះវត្តមាន ឯកឧត្តម លោក ជំទាវ លោកឧត្តមសេនីយ៍ អស់លោក លោកស្រី ដែលជាអ្នកទទួលខុសត្រូវទាំងអស់ កំពុងមានវត្តមាននៅក្នុងអង្គសន្និបាតដ៏មានសារៈសំខាន់នេះ ដែលបានខិតខំសំរេចបាននូវសមិទ្ធផលយ៉ាងធំធេងក្នុងឆ្នាំ២០០៩កន្លងមកនេះ ។

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !**

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ជាមួយទេពកោសល្យដឹកនាំដ៏វាងវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** របស់យើង បានធ្វើអោយយើងពុះពារជំនះនូវបញ្ហាប្រឈមធំៗក្នុងឆ្នាំ២០០៩កន្លងមក ហើយប្រជាជាតិ និងប្រជាជនយើងកំពុងបោះជំហានទៅមុខយ៉ាងរឹងមាំ ជាមួយសមិទ្ធផលសង្គមលើគ្រប់វិស័យ ។ ដោយឡែកចំពោះក្រសួងមហាផ្ទៃ ក៏បានប្រឹងប្រែងសំរេចបាននូវសមិទ្ធផលជាច្រើននៅក្នុងសមិទ្ធផលដែលសង្គមយើងទទួលបានក្នុងឆ្នាំ២០០៩នេះ ជាអាទិ៍ ÷

**លើវិស័យសន្តិសុខសង្គម** ក្នុងឆ្នាំ២០០៩កន្លងទៅ ទោះបីពិភពលោកកំពុងប្រឈមនឹងបញ្ហាស្មុគស្មាញជាច្រើនដូចជា: វិបត្តិសេដ្ឋកិច្ចសាកល គ្រោះធម្មជាតិ និងបញ្ហាអសន្តិសុខដោយសារអំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន ប៉ុន្តែកម្ពុជាយើងនៅតែរក្សាបានយ៉ាងរឹងមាំនូវសន្តិភាព ការឯកភាពជាតិ សន្តិសុខ ស្ថេរភាព និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងបានទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនូវអំពើភេរវកម្ម និងវិច្ឆេទកម្មនានាក្នុងសង្គមទាំងមូល ។ ប្រការនេះ បានរួមចំណែកដល់ការលើកស្ទួយនីតិរដ្ឋ ការការពារសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដើម្បីបង្កើតឡើងនូវបរិស្ថាននយោបាយ និងសន្តិសុខ ប្រកបដោយភាពអនុគ្រោះសំរាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

អំពីការរក្សាការពារបូរណភាពទឹកដី អធិបតេយ្យភាពរបស់ជាតិ កងកំលាំងនគរបាលជាតិ អាជ្ញាធរគ្រប់ថ្នាក់ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ បានចូលរួមជាមួយកងយោធពលខេមរភូមិន្ទ ខិតខំទប់ស្កាត់ប្រកបដោយប្រសិទ្ធភាព នូវសកម្មភាពប៉ុនប៉ងរំលោភឈ្លានពានពីសំណាក់កងទ័ពថៃ មកលើបូរណភាពទឹកដីរបស់យើងនៅតំបន់ព្រំដែននៃខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ក៏ដូចខ្សែបន្ទាត់ព្រំដែនភាគខាងលិចនៃប្រទេស ។ ទន្ទឹមនេះ ប្រការគួរជាទីមោទនភាពបំផុត គឺយើងមើលឃើញច្បាស់នូវទឹកចិត្តស្នេហាជាតិ ស្នេហាមាតុភូមិពីសំណាក់ប្រជាជនយើងទូទាំងប្រទេស ក្នុងការចូលរួមបរិច្ចាគធនធានផ្ទាល់ខ្លួន ទោះតិច ទោះច្រើន ជួយលើកទឹកចិត្តដល់យុទ្ធជនការពារព្រំដែន និងចូលរួមអភិវឌ្ឍព្រំដែនបានយ៉ាងសកម្មបំផុត ។

**អំពីការកែទំរង់រដ្ឋបាលថ្នាក់ក្រោមជាតិ** ឆ្នាំ២០០៩កន្លងមក គឺជាឆ្នាំដែលយើងសំរេចបានសមិទ្ធផលជាប្រវត្តិសាស្ត្រថ្មីមួយទៀត នោះគឺការសំរេចបាននូវការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបាននាំដំណើរការកំណែទំរង់នេះ អោយមកកាន់ដំណាក់កាលថ្មីមួយទៀតនោះ គឺការពង្រីកដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទាំងមូល ។ ក្រុមប្រឹក្សាដែលបានជ្រើសរើសឡើង តាមការបោះឆ្នោតអសកលកាលពីខែ ឧសភា ឆ្នាំ២០០៩កន្លងទៅ បានចូលកាន់តំណែងជាមួយនឹងការតែងតាំងគណៈអភិបាលសម្រាប់ក្រុមប្រឹក្សានៅថ្នាក់រដ្ឋបាលទាំងនេះ ។ មកទល់ពេលនេះ ក្រុមប្រឹក្សា

នៅថ្នាក់រដ្ឋបាលទាំងនេះ បានរៀបចំកិច្ចប្រជុំ ស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។ ទោះបីនៅមានការខ្វះខាតលិខិតបទដ្ឋាននានាសំរាប់អនុវត្តច្បាប់រៀបចំអង្គការ ក៏ក្រុមប្រឹក្សា និងគណៈអភិបាលនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានរួមគ្នារៀបចំរបៀបវារៈប្រជុំ ការប្រជុំ និងការចាត់ចែងអនុវត្តការងារសំខាន់ៗ ស្របតាមស្មារតីនៃច្បាប់រៀបចំអង្គការ។ ឆ្លើយតបសំណូមពរនេះ រាជរដ្ឋាភិបាលកម្ពុជាទើបនឹងសំរេចដាក់អោយអនុវត្តនូវអនុក្រឹត្យចំនួន ០៦ ។ លើមូលដ្ឋាននៃអនុក្រឹត្យទាំងនេះ ក្រសួងមហាផ្ទៃក៏បានចេញប្រកាសចំនួន ០៣ សំរាប់ជាមូលដ្ឋានក្នុងការអនុវត្តច្បាប់រៀបចំអង្គការ និងអនុក្រឹត្យថ្មីៗទាំងនេះ ។ កំណែទំរង់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមគោលការណ៏នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ជាដំណើរការកំណែទំរង់ដ៏ស៊ីជំរៅ សាំញ៉ាំ និងរសើប ដោយសារតែកំណែទំរង់នេះមានការប៉ះពាល់មកលើការកែលំអររបៀបរបបការងារ តួនាទី ភារកិច្ច សិទ្ធិអំណាច និងធនធានរបស់ស្ថាប័នរដ្ឋបាលនៅគ្រប់ថ្នាក់ ។ ហេតុនេះ កំណែទំរង់នេះ ទាមទារអោយមានការកំណត់ជំហាន ដំណាក់កាល និងទិសដៅសកម្មភាពអោយបានច្បាស់លាស់ ក្នុងរយៈពេលពីមធ្យមទៅរយៈពេលវែង ។ លើមូលដ្ឋាននេះ កម្មវិធីជាតិមួយមានរយៈពេល ១០ឆ្នាំ(២០១០-២០១៩) សំរាប់កំណត់ផែនទីបង្ហាញផ្លូវ សកម្មភាព និងការប៉ាន់ប្រមាណអំពីធនធានសំរាប់បំរើអោយកំណែទំរង់នេះ ត្រូវបានរៀបចំព្រាងឡើង ដែល គ.ជ.អ.ប និងពិនិត្យពិភាក្សាដើម្បីសុំការអនុម័តពីរាជរដ្ឋាភិបាលក្នុងពេលខាងមុខនេះ ។

កំណែទំរង់រដ្ឋបាលនៅថ្នាក់ក្រោមជាតិ តាមរយៈគោលការណ៏នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ បាននឹងកំពុងរួមចំណែកយ៉ាងធំធេងក្នុងការអភិវឌ្ឍមូលដ្ឋាន និងការចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ ធនធានពីរាជរដ្ឋាភិបាល ពីដៃគូរអភិវឌ្ឍន៏ ពីសង្គមស៊ីវិល និងពីប្រភពផ្ទាល់នៅមូលដ្ឋានកាន់តែច្រើនឡើង ត្រូវបានបង្វែរទៅមូលដ្ឋាន ដើម្បីគាំទ្រដល់គំរោងអភិវឌ្ឍន៏ និងការផ្តល់សេវាកម្មនៅមូលដ្ឋាន ដែលផ្តួចផ្តើមឡើងដោយសហគមន៏នៅមូលដ្ឋាន ហើយដែលធនធាន និងគំរោងទាំងនេះ ចាត់ចែងដោយអាជ្ញាធរមូលដ្ឋានដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើង។ ការអភិវឌ្ឍរបៀបនេះមានលក្ខណៈកាន់តែឆ្លើយតបចំពោះតម្រូវការរបស់សហគមន៏នៅមូលដ្ឋាន ដោយឈរលើគោលការណ៏គណនេយ្យភាព តម្លាភាព និងការធានាឱ្យមានសមធម៌ក្នុងការអភិវឌ្ឍ ។

ព្រមជាមួយនេះ កងកំលាំងនគរបាលជាតិ និងអាជ្ញាធរគ្រប់ជាន់ថ្នាក់ នៅរដ្ឋបាលថ្នាក់ក្រោមជាតិបានខិតខំឆ្លើយតបបានយ៉ាងទាន់ពេលវេលានូវគ្រោះមហន្តរាយនានានៅមូលដ្ឋាន ដូចគ្រោះខ្យល់ព្យុះកេតសាណា ទឹកជំនន់ គ្រោះថ្នាក់ផ្សេងៗក្នុងសង្គម អគ្គីភ័យ ។ល។ ដោយបានខិតខំឆ្លើយតបភ្លាមៗ នៅពេលមានគ្រោះមហន្តរាយ និងបានប្រមូលផ្តុំកំលាំងមនុស្សធម៌ក្នុងចំណោមមហាជនគ្រប់មូលដ្ឋាន រួមជាមួយកាកបាទក្រហមកម្ពុជា ដើម្បីរួមគ្នាជួយសង្គ្រោះដល់អ្នករងគ្រោះនានាបានទាន់ពេលវេលា ។ ទន្ទឹមនេះ អាជ្ញាធរ កងកំលាំងសមត្ថកិច្ច បានចលនាប្រជាជន ដើម្បីរួមគ្នាស្តារឡើងវិញនូវផលវិបាកនានា ដែលបណ្តាលមកពីគ្រោះមហន្តរាយ

ទាំងនេះ ធ្វើអោយស្ថានភាពជីវភាពរស់នៅរបស់ប្រជាជន និងសង្គមរបស់យើង វិលមកមានប្រក្រតីភាពឡើងវិញ ញ៉ាំងឱ្យរាជរដ្ឋាភិបាលបន្តរក្សាបាននូវកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។

ទន្ទឹមនេះ ការងារដ៏ទៃទៀតក្នុងក្របខ័ណ្ឌនៃការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ ក៏សំរេចបានសមិទ្ធផលជាច្រើន ដូចជា ការកសាងសមត្ថភាពធនធានមនុស្ស ទាំងរដ្ឋបាលស៊ីវិល នគរបាលជាតិ ការងារពន្ធនាគារ ការចុះបញ្ជីអត្រានុកូលដ្ឋាន ការចូលរួមដោះស្រាយវិវាទនៅមូលដ្ឋាន ។ល។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំថ្លែងនូវការកោតសរសើរដោយស្មោះចំពោះថ្នាក់ដឹកនាំនៃក្រសួងមហាផ្ទៃ ចំពោះថ្នាក់ដឹកនាំមន្ត្រីរាជការ នៃអង្គភាពនានា ក្នុងទីស្តីការក្រសួងមហាផ្ទៃ អាជ្ញាធរគ្រប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ មន្ត្រី ព្រមទាំងកងកំលាំងនគរបាលជាតិទាំងមូល ដែលបានធ្វើពលិកម្មយ៉ាងធំធេង ក្នុងការនាំមកនូវសមិទ្ធផលដ៏មានតម្លៃសំរាប់ប្រជាជាតិ និងប្រជាជនយើង ក្នុងឆ្នាំ២០០៩កន្លងទៅនេះ ។

**ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !**

ទន្ទឹមនឹងសមិទ្ធផលដែលសំរេចបាន យើងក៏នៅមានបញ្ហាប្រឈមជាច្រើនទៀត ក្នុងការថែរក្សាសន្តិសុខសង្គម ការកែទំរង់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបាននិងកំពុងឈានចូលមកដល់ដំណាក់កាលកាន់តែស៊ីជម្រៅថែមទៀត។

ក្នុងសន្និបាតនេះ យើងនឹងរួមគ្នាពិនិត្យមើលបញ្ហាប្រឈមសំខាន់ៗ ដែលនៅសេសសល់ ដើម្បីរិះរកវិធានការរួមគ្នា សំរាប់ដោះស្រាយបញ្ហាប្រឈមទាំងនោះ ហើយរួមគ្នាកំណត់ទិសដៅសកម្មភាពសំរាប់បន្តអនុវត្តក្នុងឆ្នាំ២០១០នេះ អោយទទួលបានសមិទ្ធផលកាន់តែល្អប្រសើរថែមទៀត ដើម្បីចូលរួមអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ។

ជាទីបញ្ចប់ក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមជូនពរ គណៈអធិបតី ឯកឧត្តម លោកជំទាវ លោកឧត្តមសេនីយ៍ អស់លោក លោកស្រី សមាជិក សមាជិការអង្គសន្និបាតទាំងមូល សូមជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺ**អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ និង **សូមប្រកាសបើកសន្និបាត ចាប់ពីពេលនេះតទៅ** ។

**សូមអរគុណ ...... !**